# គណិតវិទ្យានគរព្រះ
# Kingdom's Math

## សេចក្តីសង្ខេប:

ព្រះជាម្ចាស់ហៅយើងឱ្យថ្វាយអ្វីដែលយើងមាននៅក្នុងដៃដល់ព្រះអង្គ ទោះជាតូចយ៉ាងណាក៏ដោយ ដើម្បីឱ្យយើងមានអភ័យឯកសិទ្ធិចូលរួមជាមួយព្រះអង្គនៅក្នុងការពង្រីកនគរព្រះ។ ព្រះជាម្ចាស់ប្រើការស្តាប់បង្គាប់ដោយលះបង់របស់យើង និងចម្រើនអ្វីដែលយើងថ្វាយដល់ព្រះអង្គឱ្យច្រើនឡើង។ ព្រះគម្ពីរបង្ហាញប្រាប់ម្តងហើយម្តងទៀតថា ផ្លូវរបស់ព្រះជាម្ចាស់ដោះយើងឱ្យមានសេរីភាពរួចផុតពីការពឹងអាងលើធនធានខាងក្រៅសម្រាប់ការរីកចម្រើនឡើង និងការអភិវឌ្ឍន៍។

## គំនិតចម្បង:

១. ព្រះជាម្ចាស់តម្រូវឱ្យអ្នកជឿទាំងអស់វិនិយោគអ្វីដែលពួកគេមានសម្រាប់គោលបំណងរបស់នគរព្រះ។ ទាំងអ្នកមានតិច ទាំងអ្នកមានច្រើន សុទ្ធតែមានអ្វីសម្រាប់ថ្វាយ។

២. ព្រះជាម្ចាស់ចម្រើនអំណោយដែលយើងថ្វាយចេញពីការស្តាប់បង្គាប់ដោយសេចក្តីស្រលាញ់ ទោះបីជានៅពេលដែលយើងមិនមើលឃើញការចម្រើនជាច្រើនឡើងនោះក៏ដោយ។

៣. ការលះបង់កាន់តែធំ ការចម្រើនឡើងកាន់តែច្រើនឡើង។

៤. ព្រះជាម្ចាស់ត្រូវបានលើកតម្កើង ហើយអ្នកដទៃទៀតបានទទួលពរ តាមរយៈការថ្វាយដោយស្តាប់បង្គាប់ដោយសេចក្តីស្រលាញ់ និងដោយលះបង់។

៥. លទ្ធផលកើតចេញពីការមិនថ្វាយអ្វីដែលយើងមានដល់ព្រះជាម្ចាស់ នោះអាក្រក់ខ្លាំងណាស់។ ការចាប់តោងអ្វីដែលយើងមាន មិនព្រមវិនិយោគនៅក្នុងនគរព្រះ នោះមានគ្រោះថ្នាក់ខ្លាំងណាស់។

## លទ្ធផល:

១. ឥឡូវនេះ:

ក. យល់ និងនិយាយប្រាប់គំនិតចម្បងរបស់មេរៀន ដោយប្រើពាក្យរបស់ខ្លួនគេ។

ខ. រៀបចំផែនការ និងអនុវត្តជំហានថ្មីមួយជាការឆ្លើយតបទៅនឹងគំនិតចម្បងនៅក្នុងមេរៀននេះ ដោយលះបង់ និងស្តាប់បង្គាប់នៅក្នុងការវិនិយោគអ្វីដែលយើងមាន ដើម្បីពង្រីកនគររបស់ព្រះជាម្ចាស់ ។

២. ទៅមុខទៀត

ក. ស្គាល់អត្តសញ្ញាណធនធាផ្សេងៗដែលព្រះជាម្ចាស់បានប្រទានឱ្យរួចហើយ ប្តេជ្ញាចិត្តវិនិយោគធនធនទាំងនោះដើម្បីបម្រើអ្នកដទៃទៀត និងទទួលស្គាល់ថា ព្រះជាម្ចាស់ធ្វើឱ្យការថ្វាយរបស់ពួកគេចម្រើនឡើង ។

ខ. ធ្វើការជាអ្នកដឹកនាំដើម្បីបង្រៀន និងលើកទឹកចិត្តអ្នកជឿដទៃទៀតឱ្យថ្វាយដោយលះបង់ និងដោយស្តាប់បង្គាប់នូវអ្វីដែលពួកគេមានរួចហើយ ដើម្បីបម្រើអ្នកដទៃទៀត ។

# គណិតវិទ្យានគរព្រះ

## គ្រោងមេរៀន

## ១. រំឭកមេរៀនឡើងវិញ

## ២. សេចក្តីផ្តើម

## ៣. ខគម្ពីរគន្លឹះ៖ អេសាយ ៤០:២៩

ក. តើលោកអ្នកមានគំនិតយ៉ាងដូចម្តេចខ្លះអំពីអត្ថន័យរបស់បទគម្ពីរនេះ?

ខ. តើលោកអ្នកអាចបំឡែងខគម្ពីរនោះទៅជារូបមន្តគណិតវិទ្យាបានដែរឬទេ?

## ៤. ខគម្ពីរគាំទ្រ និងសំណួរស្វែងយល់

ក. រឿងនៅមាត់បឹង (យ៉ូហាន ៦:១-១៤, ម៉ាថាយ ១៤:២)

១. តើព្រះយេស៊ូវអាចឱ្យអាហារដល់ហ្វូងបណ្តាជនតាមរបៀបផ្សេងបានដែរឬទេ? យ៉ាងដូចម្តេច?

២. ហេតុអ្វីបានជាព្រះអង្គជ្រើសយកក្មេងប្រុស ដែលមានអាហារគ្រប់គ្រាន់សម្រាប់តែខ្លួនឯងប៉ុណ្ណោះ?

៣. សូមចាំសំណួរនេះនៅក្នុងចិត្ត នៅពេលដែលយើងបន្តមេរៀនទៅមុខទៀត។

ខ. រឿងអំពីគ្រោះទុរ្ភិក្ស ( ១ពង្សាវតារក្សត្រ ១៧:៧-១៦, ១៨:១)

១. តើព្រះជាម្ចាស់អាចឱ្យអាហារលោកអេលីយ៉ាតាមរបៀបផ្សេងបានដែរឬទេ? យ៉ាងដូចម្តេច?

២. ហេតុអ្វីបានជាព្រះជាម្ចាស់ចាត់លោកអេលីយ៉ាទៅឯស្ត្រីមេម៉ាយដែលមានអាហារគ្រប់គ្រាន់សម្រាប់តែមួយថ្ងៃទៀតប៉ុណ្ណោះ?

៣. សូមចាំសំណួរនេះនៅក្នុងចិត្ត នៅពេលដែលយើងបន្តមេរៀនទៅមុខទៀត។

គ. រឿងនៅព្រះវិហារ ( ម៉ាកុស ១២:៤១-៤៤)

១. តើព្រះយេស៊ូវមិនបានដឹងទេឬអីថា ស្ត្រីមេម៉ាយម្នាក់នេះខ្វះខាតខ្លាំងណាស់ ហើយគាត់មានតែពីរកាក់នោះប៉ុណ្ណោះ?

២. ហេតុអ្វីបានជាព្រះយេស៊ូវមិនរារាំងនាង ហើយហៅនាងឱ្យយកពីរកាក់នោះទិញអាហារបរិភោគទៅ?

៣. តើអ្នកគិតថា តាមន័យត្រង់ ស្ត្រីនោះបានថ្វាយច្រើនជាងអ្នកមានដែលបានថ្វាយនៅថ្ងៃនោះដែរឬទេ?

ចូរធ្វើតាមរូបមន្ត ហើយចាំមើលចម្លើយ។

១. តើព្រះយេស៊ូវមានការលើកលែងសម្រាប់រាស្ត្រដែលក្រនៅក្នុងនគរព្រះដែរឬទេ ទាក់ទងនឹងកាតព្វកិច្ចរបស់ពួកគេដែលត្រូវថ្វាយធនធានមួយចំនួនសម្រាប់គោលបំណងរបស់នគរព្រះ?

២. តើអ្នកក្រត្រូវការអ្វី ដើម្បីស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះយេស៊ូវឱ្យស្រលាញ់អ្នកជិតខាងរបស់ខ្លួន?

៣. នៅពេលដែលអ្នកក្រចែកចាយអ្វី ដែលពួកគេមាន តើឥរិយាបថបែបណាដែលចាំបាច់?

៤. តើមានកាលៈទេសៈណាមួយដែលអ្នកក្រមាន"តិចពេក" ឬអ្វីមួយ"ដែលមិនសំខាន់ទាល់តែសោះ" មិនអាចថ្វាយដល់ព្រះជាម្ចាស់បានដែរឬទេ?

៥. តើមានភស្តុតាងអ្វីដែលបង្ហាញថា ព្រះជាម្ចាស់ប្រទានពរដល់ការថ្វាយរបស់អ្នកក្រ?

៦. នៅពេលដែលព្រះជាម្ចាស់ប្រទានពរដល់តង្វាយរបស់អ្នកក្រ ដែលបានថ្វាយដោយជំនឿ តើព្រះជាម្ចាស់ប្រទានពរតាមលក្ខណៈ "បូក" ឬតាមលក្ខណៈ"គុណ"?

៧. តើអ្នកដែលថ្វាយដល់ព្រះជាម្ចាស់តែងតែមើលឃើញ ឬបានទទួលព្រះពរផ្ទាល់ខ្លួននៅក្នុងជីវិតនេះដែរឬទេ?

៨. ព្រះយេស៊ូវបានមានបន្ទូលថា ស្ត្រីនេះបានថ្វាយ"លើសជាង"អ្នកទាំងអស់ តើព្រះអង្គចង់មានន័យយ៉ាងដូចម្តេច?

ឃ. រូបមន្តទូទៅរបស់នគរព្រះ

ង. រឿងដែលសោកសង្រេងខ្លាំងបំផុត (ម៉ាថាយ ២៥:១៤-៣០)

១. ដោយពិចារណាបទគម្ពីរនេះ តើអ្នកគិតថា នឹងមានលទ្ធផលយ៉ាងដូចម្ដេចសម្រាប់អ្នកក្រ ប្រសិនបើពួកគេប្រើភាពក្រីក្រជាមូលហេតុ ដើម្បីមិនស្ដាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះយេស៊ូវឱ្យស្រលាញ់អ្នកជិតខាងរបស់ខ្លួននោះ? តើមានលទ្ធផលយ៉ាងដូចម្ដេចសម្រាប់អស់អ្នកមិនស្រលាញ់អ្នកជិតខាងរបស់ខ្លួន ទោះបីជាពួកគេមានហេតុផលអ្វីក៏ដោយ?

២. តើអ្នកបម្រើផ្សេងៗគ្នាប្រកបជំនឿយ៉ាងដូចម្ដេច?

## ៥. ការពង្រឹងឡើងវិញ

## ៦. ការអនុវត្តន៍

ក. សម្រេចចិត្តដើម្បីថ្វាយអ្វីមួយ

- សេចក្ដីស្រលាញ់ចំពោះព្រះជាម្ចាស់
- ជំនឿ
- ការស្ដាប់បង្គាប់ / ការថ្វាយដោយលះបង់

ខ. សរសេរការសម្រេចចិត្ត

គ. របាយការណ៍អំពីការអនុវត្តន៍ (ត្រៀមខ្លួនដើម្បីចែកចាយរបាយការណ៍នៅពេលចាប់ផ្ដើមរៀនលើកក្រោយទៀត) ។

# គណិតវិទ្យានគរព្រះ

## មេរៀន

សេចក្តីពិតដែលថា ព្រះជាម្ចាស់ធ្វើឱ្យតង្វាយបន្តិចបន្តួចរបស់យើងចម្រើនច្រើនឡើង មានអំណាចខ្លាំងណាស់ ប្រសិនបើសេចក្តីពិតដក់ជាប់នៅក្នុងចិត្ត។

យុវជនមួយក្រុមកំពុងបម្រើដល់អ្នកអនាថានៅតាមផ្លូវក្នុងទីក្រុងអាឌីស អាបាបា ប្រទេសអេធីយ៉ូពី។ អ្នកដឹកនាំរបស់ពួកគេពីរនាក់បានចូលរៀននៅក្នុងសិក្ខាសាលាមួយរបស់យើង ហើយពួកគេបានឮថា ព្រះជាម្ចាស់ធ្វើឱ្យតង្វាយស្ម័គ្រចិត្តរបស់កូនព្រះអង្គចម្រើនច្រើនឡើង។ ពេលមានសិក្ខាសាលានោះ ពួកគេកំពុងបង្កើតមិត្តជាមួយក្មេងអនាថានៅតាមផ្លូវ។ ពីរឆ្នាំក្រោយមក ពួកគេមានអង្គការធំមួយដែលមានបុគ្គលិកសែសិបនាក់ និងអ្នកស្ម័គ្រចិត្ត ព្រមទាំងយុទ្ធសាស្ត្រផ្សេងៗដែលមានចាប់តាំងពីការឈប់ឱ្យមានអ្នកអនាថានៅតាមផ្លូវ រហូតដល់ការកែប្រែស្ត្រីពេស្យា។ នៅពេលដែលសួរអំពីដំណើរការនេះកើតឡើង ពួកគេបានឆ្លើយតបថា "គណិតវិទ្យានគរព្រះ!"។ ពួកគេបានធំឡើងនៅក្នុងពួកជំនុំមួយដែលរឹងមាំ ប៉ុន្តែវប្បធម៌របស់ពួកគេជឿថា ការលុបបំបាត់ភាពក្រីក្រអាចចាប់ផ្តើមឡើងបាន ទាល់តែមានធនធានមកពីក្រៅ។ ពួកគេបានឮរឿងជាច្រើននៅក្នុងព្រះគម្ពីរដែលនិយាយអំពីព្រះចេស្តារបស់ព្រះជាម្ចាស់ក្នុងការធ្វើឱ្យធនធានចម្រើនច្រើនឡើង ប៉ុន្តែពិបាករំលាយសេចក្តីពិតនោះចូលមកក្នុងខ្លួន រហូតមកដល់ពេលឥឡូវនេះ។

ផ្នត់គំនិតពឹងផ្អែកលើគេបានឃុំឃាំងពួកជំនុំជាច្រើននៅក្នុងប្រទេសតតិយលោកនៅសព្វថ្ងៃនេះ ប៉ុន្តែយើងបានមើលឃើញព្រះជាម្ចាស់ប្រើសេចក្តីពិតនៅក្នុងសារនេះ ដើម្បីរំដោះអ្នកដឹកនាំពួកជំនុំជាច្រើនឱ្យរួចផុតពីចំណងនៃការពឹងផ្អែកលើអ្នកដទៃ។ ដូចគ្នាដែរ ឥរិយាបថដែលថា ការលះបង់បម្រើតាមបែបសាមញ្ញរបស់យើងមិនគ្រប់គ្រាន់នឹងធ្វើឱ្យមានការផ្លាស់ប្តូរយូរអង្វែងនៅក្នុងសហគមន៍ដែលបាក់បែក បានធ្វើពួកជំនុំនៅក្នុងប្រទេសអភិវឌ្ឍពិការ។ ប៉ុន្តែការយល់ដឹងអំពីគណិតវិទ្យានគរព្រះបានលើកទឹកចិត្តពួកជំនុំដែលតូចជាងគេ ឬក្រជាងគេ ឱ្យធ្វើអ្វីដែលហាក់បីដូចជាមិនអាចធ្វើបាន។ ព្រះជាម្ចាស់ចង់ប្រើពួកជំនុំធ្វើជាទសម្រាប់ឱ្យអំណាចបំផ្លាស់បំប្រែរបស់ព្រះអង្គហូរមក ប៉ុន្តែព្រះអង្គមិនអាចធ្វើការនោះបានទេ នៅពេលដែលពួកជំនុំកំពុងពឹងផ្អែកលើប្រភពផ្សេងៗជាជាងព្រះជាម្ចាស់។ មែនហើយ ព្រះជាម្ចាស់អាចប្រើធនធាន"ខាងក្រៅ"បាន ប៉ុន្តែនៅពេលដែលពួកជំនុំមើលទៅអ្វីផ្សេងជាជាងព្រះជាម្ចាស់ ជាប្រភពសម្រាប់ការប្រោសឱ្យជា ទោះជានៅក្នុងគំនិត ឬនៅក្នុងការប្រព្រឹត្ត នោះមានគ្រោះថ្នាក់ខិតទៅរកការថ្វាយបង្គំរបស់ដែលត្រូវបានបង្កើតមក ជាជាងអ្នកបង្កើត។ មានន័យថា ការសម្លឹងមើលទៅខាងក្រៅជំនួសឱ្យព្រះជាម្ចាស់ គឺជាការថ្វាយបង្គំរូបព្រះ ដោយមិនដឹងខ្លួន។

គណិតវិទ្យានគរព្រះបានជួយពួកជំនុំនៅប្រទេសអេធីត្យូពី និងអ្នកដឹកនាំរបស់ពួកគេ។ តើអ្វីទៅជាគណិតវិទ្យានគរព្រះ? សូមមើលរឿងមួយចំនួននៅក្នុងព្រះគម្ពីរ ដើម្បីរៀនអំពីរបៀបដែលព្រះជាម្ចាស់នាំមកនូវការបំផ្លាស់បំប្រែយ៉ាងអស្ចារ្យ។

## កំឡាំងរបស់ព្រះជាម្ចាស់

បទគម្ពីរទីមួយដែលយើងនឹងមើលគឺ អេសាយ ៤០:២៩។ បទគម្ពីរនោះប្រាប់ថា "ទ្រង់រមែងចំរើនកំឡាំងដល់អ្នកដែលល្វើយ ហើយចំណែកអ្នកដែលគ្មានកំឡាំងសោះ នោះទ្រង់ក៏ប្រទាន"។ បទគម្ពីរនេះអាចមើលទៅមានលក្ខណៈបែបខាងក្រោមនេះ តាមសមីកាគណិតវិទ្យានគរព្រះ។

**ភាពកម្សោយរបស់យើង x ព្រះជាម្ចាស់ = កំឡាំង**

សារគណិតវិទ្យានគរព្រះត្រូវបានសង្ខេបនៅក្នុងបទគម្ពីរដ៏ខ្លីនេះ។ នៅពេលដែលយើងថ្វាយភាពកម្សោយរបស់យើងដល់ព្រះជាម្ចាស់ ព្រះអង្គបំផ្លាស់បំប្រែភាពកម្សោយនោះឱ្យទៅជាកំឡាំងវិញ។ ផ្នែកផ្សេងទៀតរបស់បទគម្ពីរនេះប្រាប់ថា "ទោះទាំងពួកជំទង់ គេនឹងល្វើយ ហើយនឿយហត់ទៅបាន ពួកកំឡោះក៏នឹងដួលជ្រលាកបានផង តែអស់អ្នកណាដែលសង្ឃឹមដល់ព្រះយេហូវ៉ាវិញ នោះនឹងមានកំឡាំងចំរើនជានិច្ច គេនឹងហើរឡើងទៅលើ ដោយស្លាបដូចសត្វឥន្ទ្រី គេនឹងរត់ទៅឥតដែលហត់ ហើយនឹងដើរឥតដែលល្វើយឡើយ" (អេសាយ ៤០:៣០-៣១)។ "ការបំផ្លាស់បំប្រែ"នេះមិនមែនជាការបំផ្លាស់បំប្រែធម្មតាទេ នោះគឺជាការអស្ចារ្យ។ គណិតវិទ្យានគរព្រះមិនមែនជាទស្សនវិទ្យាដែលនិយាយថា "បើអ្នកជឿល្មមលើខ្លួនឯង ឬលើអំណាចរបស់ការគិតបែបវិជ្ជមាន អ្នកអាចផ្លាស់ប្តូរកាលៈទេសៈរបស់អ្នកបាន"។ គណិតវិទ្យានគរព្រះចាប់ផ្តើមជាមួយការទទួលស្គាល់ថា យើងខ្សោយ និងមិនគ្រប់គ្រាន់ទេ។ សូម្បីតែពួកជំទង់ និងពួកកំឡោះក៏ជំពប់ដួលដែរ។ នៅពេលដែលយើងត្រៀមខ្លួនរួចជាស្រេចដើម្បីទទួលស្គាល់ភាពកម្សោយរបស់យើង យើងនៅកន្លែងមួយដែលនឹងមកឯព្រះជាម្ចាស់ ហើយថ្វាយភាពកម្សោយរបស់យើង។ បន្ទាប់មក ព្រះអង្គនឹងធ្វើការអស្ចារ្យតាមគណិតវិទ្យានគរព្រះ ហើយបំផ្លាស់បំប្រែភាពមានដែនកំណត់របស់យើងឱ្យទៅជាព្រះចេស្តារបស់ព្រះអង្គ។

មានរឿងជាច្រើននៅក្នុងព្រះគម្ពីរអាចបំឡែងទៅជាសមីកាគណិតវិទ្យានគរព្រះ ប៉ុន្តែយើងនឹងពិចារណាតែបួនរឿងប៉ុណ្ណោះ។ នៅចុងបញ្ចប់នៃរឿងនិមួយៗ យើងនឹងបង្កើតសមីកាមួយ។ នៅពេលបញ្ចប់រឿងទាំងអស់ យើងនឹងរកឃើញសេចក្តីពិត ដើម្បីជួយដោះយើងឱ្យរួចផុតពីការពឹងផ្អែកលើអ្នកដទៃ និងជម្ងឺស្វិតដៃជើង។

## រឿងនៅមាត់បឹង:

នេះគឺជារឿងសំដែងទីមួយ ដកស្រង់ចេញពីយ៉ូហាន ៦:១-១៤ និងម៉ាថាយ ១៤:១៣-២១។ មានក្មេងប្រុសម្នាក់អាយុ ១០ឆ្នាំ ឈ្មោះថា ធារ៉ា គាត់បានឮថា មានគ្រូបង្រៀនដ៏ល្បីល្បាញម្នាក់កំពុងបង្រៀនមនុស្សនៅមាត់បឹង។ គាត់បានអង្វរសុំម្តាយទៅមើល។ នៅចុងបញ្ចប់ ម្តាយក៏យល់ព្រម ហើយយកក្រមាមកវិចអាហារថ្ងៃត្រង់ដែលមាននំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយ។ នៅពេលដែលធារ៉ាបានទៅដល់បឹង គាត់បានប្រច្រៀតកាត់ហ្វូងមនុស្សទៅដល់ខាងមុខ។ ធារ៉ាមិនបានយល់គ្រប់សេចក្តីទេ ប៉ុន្តែគាត់ចាប់អារម្មណ៍នឹងគ្រូបង្រៀននេះយ៉ាងខ្លាំង។ នៅពេលដែលគាត់ឃ្លាន គាត់បានស្រាយយកអាហារថ្ងៃត្រង់ដោយប្រុងប្រយ័ត្ន។ នៅពេលនោះ មានសិស្សម្នាក់របស់លោកគ្រូបានសុំឱ្យលោកគ្រូប្រាប់មនុស្សឱ្យទៅរកអ្វីបរិភោគសិនទៅ។ប៉ុន្តែ លោកគ្រូបាននិយាយថា "ពួកគេមិនត្រូវទៅឆ្ងាយទេ សូមអ្នកឱ្យអាហារគេបរិភោគទៅ!"។ សិស្សម្នាក់ឈ្មោះ អនទ្រេ បានឃើញអាហារថ្ងៃត្រង់របស់ធារ៉ា។ អន់ទ្រេបានប្រាប់ថា "លោកគ្រូយើងមានតែនំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយតែប៉ុណ្ណោះ"។ ព្រះយេស៊ូវមានបន្ទូលថា "ចូរយកអាហារនោះមកឱ្យខ្ញុំ"។ ខ្ញុំមិនដឹងថា ធារ៉ាគិតយ៉ាងដូចម្តេចទេ ប៉ុន្តែគាត់បានឱ្យអាហារថ្ងៃត្រង់ទៅព្រះយេស៊ូវ ព្រះអង្គបានអរព្រះគុណ ហើយចាប់ផ្តើមកាច់នំបុ័ងឱ្យទៅហ្វូងបណ្តាជន។ ចូរស្រមៃមើលធារ៉ាប្រាប់ម្តាយរបស់គាត់ពេលក្រោយមកទៀតថា "លោកគ្រូបានយកអាហារថ្ងៃត្រង់របស់ខ្ញុំ ហើយកាច់ចែកដល់មនុស្សទាំងអស់ ហើយសល់ដប់ពីរកន្ត្រក!"។

តើលោកអ្នកនឹងមានអារម្មណ៍យ៉ាងដូចម្តេច ប្រសិនបើលោកអ្នកគឺជាធារ៉ា? តើលោកអ្នកនឹងគិតយ៉ាងដូចម្តេច ប្រសិនបើព្រះយេស៊ូវសុំអាហារទាំងអស់ដែលលោកអ្នកមានសម្រាប់នឹងបរិភោគ? តើព្រះយេស៊ូវមិនអាចឱ្យអាហារដល់ហ្វូងបណ្តាជនតាមរបៀបផ្សេងទៀតបានទេឬ? ព្រះអង្គអាចធ្វើបាន ប៉ុន្តែព្រះអង្គមិនធ្វើ។ ផ្ទុយទៅវិញ ព្រះអង្គបានសុំក្មេងប្រុសម្នាក់ឱ្យថ្វាយអ្វីទាំងអស់ដែលក្មេងនោះមាន។ នេះគឺជាសមីកាដែលបង្ហាញឱ្យឃើញការចម្រើនច្រើនឡើងយ៉ាងហោចណាស់ ៥000 ដង។

ក្មេងប្រុស

\+ នំប៉ុងប្រាំដុំ និងត្រីពីរកន្ទុយ

x ព្រះយេស៊ូវ

---

= អាហារសម្រាប់មនុស្ស ៥000 នាក់

\+ អាហារសម្រាប់ស្ត្រី និងកូនក្មេង

\+ នំប៉ុងនៅសល់ ១២ កន្ត្រក

## រឿងអំពីគ្រោះទុរ្ភិក្ស

នេះគឺជារឿងទីពីរដកស្រង់ចេញពី ១ ពង្សាវតារក្សត្រ ១៧-១៨:១។ លោកអេលីយ៉ាបានហៅឱ្យមានគ្រោះទុរ្ភិក្សជាការដាក់ទោសសម្រាប់សេចក្តីទុច្ចរិតនៅក្នុងអ៊ីស្រាអែល។ គ្រោះទុរ្ភិក្សមានរយៈពេលជាងបីឆ្នាំ ហើយស្តេចអ័ហាប់កំពុងដេញតាមចាប់គាត់។ ព្រះជាម្ចាស់បានឱ្យលោកអេលីយ៉ាទៅពួននៅក្បែរជ្រោះមួយ ហើយផ្គត់ផ្គង់អាហារឱ្យគាត់ ដោយប្រើសត្វក្អែក។ នៅពេលដែលជ្រោះនោះរីងស្ងួត ព្រះជាម្ចាស់បានចាត់លោកអេលីយ៉ាឱ្យទៅក្រុងមួយដែលនៅឆ្ងាយ។ គាត់ស្រេកទឹក និងឃ្លានខ្លាំងណាស់ ពេលដែលគាត់បានទៅដល់ក្រុងនោះ ហើយសុំស្ត្រីម្នាក់ឱ្យជួយ ដោយដំបូងសូមទឹកផឹក បន្ទាប់មកសូមអ្វីបរិភោគ។ ស្ត្រីនោះក្រខ្លាំងណាស់ គាត់បានយកទឹកមកឱ្យ បន្ទាប់មកនិយាយថា "ខ្ញុំមានតែម្សៅ និងប្រេងសម្រាប់ធ្វើអាហារមួយពេលចុងក្រោយសម្រាប់ខ្ញុំ និងកូនប្រុសរបស់ខ្ញុំប៉ុណ្ណោះ"។ លោកអេលីយ៉ាបានអះអាងនឹងនាងថា ព្រះជាម្ចាស់នឹងផ្គត់ផ្គង់។ ដោយជំនឿ ស្ត្រីនោះបានយកម្សៅដែលនៅសល់ និងប្រេងមកធ្វើអាហារឱ្យលោកអេលីយ៉ា។ អស្ចារ្យខ្លាំងណាស់ ម្សៅ និងប្រេងនៅតែមាននៅក្នុងខាប់ និងនៅក្នុងដប គ្រប់គ្រាន់ល្មមសម្រាប់ជាអាហារដល់ស្ត្រី កូនប្រុសរបស់នាង លោកអេលីយ៉ា និងអ្នកដទៃទៀត រហូតដល់គ្រោះទុរ្ភិក្សបានចប់។ ម្តងទៀត នេះគឺជាសមីការដែលបង្ហាញឱ្យឃើញពីការចម្រើនច្រើនឡើងជាង ៦000 ដង។

ស្ត្រីមេម៉ាយ

\+ នំ ១

x ព្រះជាម្ចាស់

---

= នំ ១ (អាហារមួយពេល) រៀងរាល់ថ្ងៃ

x មនុស្ស ៣ នាក់ (នាង កូនប្រុសរបស់នាង លោកអេលីយ៉ា)

x ២ ពេលក្នុងមួយថ្ងៃ

x ៣៦៥ ថ្ងៃ

x គ្រោះទុរ្ភិក្សរយៈពេល ២.៥ ឆ្នាំ

---

= ៥,៤៧៥ នំ (អាហារ)

ការដែលអស្ចារ្យជាងការចម្រើនច្រើនឡើងនោះ គឺជារបៀបដែលព្រះជាម្ចាស់បានចិញ្ចឹមអ្នកបម្រើរបស់ព្រះអង្គ។ តើព្រះជាម្ចាស់មិនអាចចិញ្ចឹមលោកអេលីយ៉ាតាមរបៀបផ្សេងបានទេឬអី? បាន ប៉ុន្តែព្រះអង្គបានបែរមករកស្ត្រីមេម៉ាយម្នាក់ដែលមានគ្រប់គ្រាន់ល្មមសម្រាប់តែខ្លួននាង និងកូនប្រុសរបស់នាងប៉ុណ្ណោះ។

## រឿងនៅព្រះវិហារ

នេះគឺជារឿងទីបីដកស្រង់ចេញពីម៉ាកុស ១២:៤១-៤៤។ ព្រះយេស៊ូវនៅក្នុងព្រះវិហារ សង្កេតមើលមនុស្សថ្វាយតង្វាយរបស់ពួកគេ។ អ្នកមានឈរត្រង់ អួតបង្ហាញការថ្វាយតង្វាយរបស់ពួកគេ។ ស្ត្រីមេម៉ាយក្រីក្រម្នាក់បានព្យាយាមមិនឱ្យគេឃើញ នៅពេលនាងបានថ្វាយតង្វាយ ២ កាក់ ជាអ្វីៗទាំងអស់ដែលនាងមាន។ ព្រះយេស៊ូវបានឃើញនាង។ ព្រះអង្គអាចអន្តរាគមបាន ដោយប្រាប់នាងថា ព្រះជាម្ចាស់មិនត្រូវការតង្វាយតិចតួចរបស់នាងទេ។ ព្រះអង្គមិនបានអន្តរាគមទេ ក៏មិនបានមានបន្ទូលជាមួយស្ត្រីមេម៉ាយនោះដែរ។ ប៉ុន្តែ ព្រះអង្គបានមានបន្ទូលថា "ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា ស្រីមេម៉ាយក្រនេះបានថ្វាយលើសជាងអ្នកទាំងអស់ដែលដាក់ក្នុងឃ្លាំង" (ម៉ាកុស ១២:៤៣)។ ប្រាកដណាស់ <u>តាមសមាមាត្រ</u> នាងបានថ្វាយច្រើនជាងអ្នកមានថ្វាយ ពីព្រោះនាងបានថ្វាយទាំងអស់ដែលនាងមាន។ <u>អត្ថានុរូប</u> នាងក៏បានថ្វាយច្រើនជាងអ្នកមានដែរ ដូចដែលបានឃើញនៅក្នុងសមីការខាងក្រោម:

ស្ត្រីមេម៉ាយ

\+ ២ កាក់

x ព្រះយេស៊ូវ

---

= ការលើកទឹកចិត្តរយៈពេល ២000 ឆ្នាំ អំពីការថ្វាយដោយលះបង់

តើតង្វាយរបស់ស្ត្រីមេម៉ាយនេះបានចម្រើនច្រើនឡើងប៉ុន្មានលានដងនៅក្នុងរយៈពេល ២000ឆ្នាំ? គ្រីស្ទបរិស័ទគ្រប់ជំនាន់បានថ្វាយដោយលះបង់ ដោយព្រោះតែគំរូរបស់នាង។ ក្រៅពីរឿងអំពីឈើឆ្កាង រឿងនេះគឺជារឿងដែលអស្ចារ្យជាងគេអំពីការចម្រើនច្រើនឡើងនៅក្នុងបទគម្ពីរទាំងមូល!

រឿងទាំងបីនេះអាចចងក្រងចូលគ្នាទៅជាសមីកាទូទៅមួយនៅក្នុងនគរព្រះៈ

មនុស្សទាំងអស់ (សូម្បីតែអ្នកក្រ)

\+ ជំនឿលើព្រះជាម្ចាស់

\+ ការថ្វាយដោយលះបង់

\+ ការថ្វាយនៅពេលដែលសុំ

x ព្រះជាម្ចាស់

---

= ការចម្រើនច្រើនឡើងដោយសារព្រះជាម្ចាស់

\+ ព្រះពរសម្រាប់អ្នកដទៃទៀត

\+ ព្រះជាម្ចាស់ត្រូវបានសរសើរតម្កើង

\+ ព្រះពរផ្ទាល់ខ្លួន (ពេលខ្លះ)

ជីវិតរបស់ព្រះយេស៊ូវតែងតែបែបនេះ។ ព្រះអង្គមានទ្រព្យសម្បត្តិលោកិយតិចតួចណាស់។ ព្រះអង្គបានមានបន្ទូលថា "កញ្ជ្រោងមានរូងវា ហើយសត្វហើរលើអាកាសក៏មានសំបុក តែកូនមនុស្សគ្មានកន្លែងណានឹងកើយក្បាលទេ" (ម៉ាថាយ ៨:២០)។ ប៉ុន្តែ ព្រះអង្គបានថ្វាយដោយលះបង់ជាងគេ គឺជាជីវិតរបស់ព្រះអង្គ។ តង្វាយរបស់ព្រះអង្គបាននាំ

មកនូវព្រះពរអស់កល្បជានិច្ចរយៈពេល ២០០០ ឆ្នាំមកហើយសម្រាប់អស់អ្នកដែលសុំ ហើយជឿ ដោយបានថ្វាយសិរីល្អយ៉ាងអស្ចារ្យដល់ព្រះជាម្ចាស់។

## រឿងដែលសោកសង្រេងខ្លាំងបំផុត

នេះគឺជារឿងចុងក្រោយ ប៉ុន្តែជារឿងមួយដែលបញ្ចប់ដោយមិនប្រសើរទេ។ ព្រះយេស៊ូវបានមានបន្ទូលរឿងប្រៀបធៀបនេះនៅក្នុងម៉ាថាយ ២៥:១៤-៣០ ដើម្បីពន្យល់អំពីនគររបស់ព្រះអង្គ។ មានអ្នកមានម្នាក់បានហៅអ្នកបម្រើគាត់បីនាក់មកដើម្បីណែនាំ មុនពេលដែលគាត់ចេញដំណើរទៅឆ្ងាយ។ គាត់បានប្រគល់ធនធានខ្លះរបស់គាត់ឱ្យទៅម្នាក់ៗ ដោយរំពឹងថានឹងទទួលបានចំណេញ ពេលដែលគាត់ត្រលប់មកវិញ។ អ្នកបម្រើទាំងបីនាក់បានទទួលម្នាក់ ៥ ពាន់ ម្នាក់ ៣ពាន់ និងម្នាក់ទៀត ១ពាន់។ នៅពេលដែលអ្នកមាននោះបានត្រលប់មកវិញ គាត់បានឱ្យអ្នកបម្រើទាំងនោះរៀបរាប់ប្រាប់ពីលទ្ធផលរបស់ពួកគេ។ អ្នកដែលបានទទួល ៥ពាន់ និងអ្នកដែលបានទទួល ២ពាន់ បានរៀបរាប់ថាបានចំណេញ ហើយត្រូវបានអញ្ជើញឱ្យក្លាយទៅជាសមាជិកនៅក្នុងគ្រួសាររបស់អ្នកមាននោះ។ អ្នកបម្រើដែលបានទទួល ១ពាន់ ត្រូវសារភាពថា ការភ័យខ្លាចរបស់គាត់បានធ្វើឱ្យគាត់ការពាររបស់បន្តិចបន្តួចដែលគាត់មាន ដោយជីកដីកប់ មិនព្រមប្រថុយទៅរកស៊ីទេ។ អ្នកបម្រើនោះមិនត្រឹមតែត្រូវចៅហ្វាយស្តីបន្ទោសឱ្យប៉ុណ្ណោះទេ ថែមទាំងត្រូវបដិសេធមិនឱ្យនៅក្នុងគ្រួសាររបស់ចៅហ្វាយទៀតផង។ តើចៅហ្វាយនោះមិនអាចមេត្តាបន្តិចដល់អ្នកបម្រើ "ក្រីក្រ" នោះបានទេឬអី? តើគាត់ត្រូវតែសាហាវដែរឬទេ? សូមពិចារណាសមីការនេះ:

អ្នកបម្រើ

\+ ១ ពាន់

x សូន្យ

---

= សូន្យ

\+ អ្នកបម្រើត្រូវបោះទៅក្នុងទីងងឹតដែលនៅខាងក្រៅ

## មេរៀនសម្រាប់គ្រីស្ទបរិស័ទ និងពួកជំនុំមូលដ្ឋានទាំងអស់

រឿងទាំងបួននេះមានមេរៀនសំខាន់ៗសម្រាប់គ្រីស្ទបរិស័ទទាំងអស់ ប៉ុន្តែជាពិសេសសម្រាប់អ្នកដែលជឿថា អ្វីដែលពួកគេមានគឺគ្រប់គ្រាន់សម្រាប់តែខ្លួនពួកគេប៉ុណ្ណោះ។ តើមេរៀនទាំងនោះមានអ្វីខ្លះ?

ដោយមិនពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ ឬឋានៈនៅក្នុងជីវិតឡើយ មនុស្សទាំងអស់ត្រូវបានត្រាស់ហៅឱ្យថ្វាយដល់ព្រះជាម្ចាស់នូវអ្វីដែលពួកគេមាន។ គ្មានករណីលើកលែងទេ សូម្បីតែអ្នកក្រក៏ដោយ។ គ្មានកាលៈទេសៈណាមួយដែលថា អ្វីដែលយើងមាននោះ"តិចពេក" ឬ"មិនសំខាន់" សម្រាប់ឱ្យព្រះជាម្ចាស់ប្រើនោះឡើយ។ យើងត្រូវថ្វាយដល់ព្រះជាម្ចាស់ នៅពេលដែលព្រះអង្គសុំយើង។ កាលៈទេសៈនៅពេលបច្ចុប្បន្នរបស់យើងមិនមែនជាការដោះសាទេ។ ទោះជាយើងនៅកន្លែងណាក៏ដោយ យើងជាអ្វីក៏ដោយ យើងត្រូវថ្វាយ នៅពេលដែលព្រះជាម្ចាស់សុំ។ បំណងចិត្តរបស់យើងនៅក្នុងការថ្វាយគួរតែជាជំនឿលើព្រះជាម្ចាស់ និងសេចក្ដីស្រលាញ់ចំពោះព្រះជាម្ចាស់ មិនមែនដើម្បីឱ្យបានទ្រព្យសម្បត្តិកាន់តែច្រើនទេ។ ការចំណេញ និងការផ្គត់ផ្គង់ប្រហែលជាមានមែន ប៉ុន្តែការថ្វាយរបស់យើងមិនគួរដោយសារចិត្តរំពឹងចង់បានព្រះពរនោះទេ។

នៅក្នុងរឿងទាំងអស់នេះ ព្រះជាម្ចាស់គឺជាអ្នកដែលបានសុំឱ្យថ្វាយ។ ការថ្វាយដោយលះបង់ និងដោយស្ដាប់បង្គាប់ដល់ព្រះជាម្ចាស់នាំទៅរកការចម្រើនច្រើនឡើង។ យើងមិនអាចថ្វាយដល់ព្រះជាម្ចាស់ដោយស្ដាប់បង្គាប់ ហើយគ្មានការចម្រើនច្រើនឡើងនោះទេ។ ការលះបង់កាន់តែធំ ការចម្រើនឡើងកាន់តែច្រើន។ សេចក្ដីស្រលាញ់របស់ព្រះអង្គហៅឱ្យមានការលះបង់។ ការលះបង់ដោយសេចក្ដីស្រលាញ់ និងដោយស្ដាប់បង្គាប់នាំឱ្យព្រះចេស្ដារបស់នគរព្រះហូរមក ទាំងសម្រាប់វីរៈបុរសនៅក្នុងរឿងទាំងនេះ ទាំងសម្រាប់យើង។ ព្រះជាម្ចាស់ស្រលាញ់យើង និងចង់ឱ្យយើងក្លាយទៅជាមួយផ្នែកនៃអ្វីដែលព្រះអង្គកំពុងធ្វើនៅលើផែនដី។ ព្រះអង្គមិនចង់ឱ្យយើងធ្វើកិច្ចការនោះដោយខ្លួនឯងទេ ហើយព្រះអង្គមិនបានជ្រើសរើសធ្វើកិច្ចការដោយព្រះអង្គទ្រង់ទេ។ ព្រះជាម្ចាស់កំពុងរកមនុស្សដែលនឹងធ្វើចំណែករបស់ពួកគេ ហើយពឹងផ្អែកទាំងស្រុងលើព្រះអង្គ ដើម្បីនាំយកសេចក្ដីសង្ឃឹម និងជីវិតឱ្យពិភពលោកដែលបាក់បែក។ ការត្រាស់ហៅឱ្យលះបង់ចេញមកពីព្រះជាម្ចាស់ដែលស្រលាញ់យើង គឺមកពីព្រះជាម្ចាស់ដែលជាសេចក្ដីស្រលាញ់។

មេរៀនចុងក្រោយនេះពិបាក។ ប្រសិនបើយើងមិនវិនិយោគអ្វីដែលព្រះជាម្ចាស់បានប្រគល់មកឱ្យយើងទេ យើងមិនត្រឹមតែបាត់បង់របស់នោះប៉ុណ្ណោះទេ ថែមទាំងប្រថុយនឹងត្រូវបោះទៅខាងក្រៅផ្ទះរបស់ចៅហ្វាយទៀតផង។ ការមិនស្ដាប់បង្គាប់មានគ្រោះថ្នាក់ខ្លាំងណាស់។

តើរឿងទាំងនេះអាចបង្រៀនអ្វីដល់ពួកជំនុំមូលដ្ឋានរបស់យើងបាន ជាពិសេសអ្នកដែលមានទ្រព្យសម្បត្តិតិច និងលុយតិច? នេះគឺជាការប្រាប់ដោយប្រយោលមួយចំនួន។ យើងមិនមែនគ្មានអំណាចទេ។ ព្រះជាម្ចាស់នឹងយកអ្វីដែលថ្វាយដោយស្ដាប់បង្គាប់ និងដោយសេចក្ដីស្រលាញ់ ហើយចម្រើនតង្វាយឱ្យកើនច្រើនឡើង ដើម្បីថ្វាយសិរីល្អដល់ព្រះអង្គទ្រង់ និងពង្រីកនគររបស់ព្រះអង្គ។ ការលះបង់ថ្វាយធនធានពួកជំនុំដើម្បីបង្ហាញចេញព្រះហឫទ័យអាណិត

អាសូររបស់ព្រះជាម្ចាស់ចំពោះសេចក្តីត្រូវការរបស់មនុស្សដទៃទៀត នឹងមានឥទ្ធិពលមកលើពួកជំនុំ និងមនុស្សដែលនៅខាងក្រៅនគរព្រះ។ គណិតវិទ្យានគរព្រះបង្រៀនមនុស្សឱ្យថ្វាយ។ ការដែលមិនបង្រៀន និងមិនលើកទឹកចិត្តគ្រីស្ទបរិស័ទឱ្យធ្វើកិច្ចការនេះ គឺប្លន់ពួកគេយកព្រះពរដែលព្រះជាម្ចាស់ចង់ប្រទានឱ្យ។ ពួកជំនុំគួរតែឆ្លុះបញ្ចាំងឱ្យឃើញការថ្វាយដោយលះបង់ចេញពីសមាជិករបស់ខ្លួន។

នៅចុងបញ្ចប់ យើងមិនគួរខ្លាចទេ។ អ្នកបម្រើពីរនាក់ដែលបានទទួល ៥ពាន់ និង ២ពាន់ បានប្រកបជំនឿថា "ប្រថុយ" ខណៈពេលដែលអ្នកបម្រើមាន ១ពាន់ បានប្រកបជំនឿបែបផ្សេង "ភ័យខ្លាច"។ ពួកជំនុំត្រូវតែក្លាហាននៅក្នុងការបង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់។ ចូរយើងហ៊ានប្រថុយសម្រាប់នគរព្រះ ដោយចង់ចាំថា អ្វីដែលយើងប្រថុយ មិនមែនជារបស់យើងទេ ប៉ុន្តែជាអ្វីដែលបានប្រគល់មកឱ្យយើង។ ព្រះជាម្ចាស់ប្រទានឱ្យយើងនូវអ្វីទាំងអស់ដែលយើងត្រូវការ ដើម្បីលើកតម្កើងព្រះអង្គ។ បទគម្ពីរប្រាប់យើងថា "ដ្បិតព្រះចេស្តានៃព្រះបានផ្តល់ឱ្យយើងរាល់គ្នាមានគ្រប់របស់ទាំងអស់ខាងឯជីវិត និងសេចក្តីគោរពប្រតិបត្តិដល់ព្រះ ដោយយើងបានស្គាល់ព្រះអង្គ ដែលទ្រង់ហៅយើងរាល់គ្នាមក ដោយសារសិរីល្អ និងសគុណរបស់ទ្រង់" (២ ពេត្រុស ១:៣)។

មានសង្ឃឹម។ នោះមិនមែនជាសេចក្តីសង្ឃឹមដោយងងឹតងងុលទេ គឺជាសេចក្តីសង្ឃឹម ដោយដឹងប្រាកដថា ព្រះជាម្ចាស់មានផែនការ ហើយព្រះអង្គលើកតម្កើងភាពស្មោះត្រង់របស់កូនព្រះអង្គ ដោយចម្រើនតង្វាយដែលថ្វាយដោយលះបង់ និងដោយសេចក្តីស្រលាញ់ឱ្យកើនច្រើនឡើង។ នេះគឺជាផ្លូវរបស់ព្រះជាម្ចាស់ នេះគឺជាគណិតវិទ្យានគរព្រះ។

*By Bob Moffitt, Harvest Foundation*

*Last edited by Nadia Chandler and Karla Tesch, August, 2007.*

*Copyright 2007 by the Disciple Nations Alliance*

*701 N. 1st Street Phoenix, AZ 85004*

*email: bmoffitt@harvestfoundation.org*

*www.harvestfoundation.org and www.disciplenations.org*

*ការអនុញ្ញាត: លោកអ្នកត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឱ្យថតចម្លង និងចែកចាយមេរៀននេះតាមទម្រង់ណាមួយក៏បាន តែសូមកុំកែន័យមេរៀន កុំគិតថ្លៃហួសពីលោកអ្នកចំណាយ និងកុំថតចម្លងច្រើនជាង ១000 ច្បាប់។*

## ធនធានល្អដែលបានផ្ដល់ជាយោបល់ជូនៈ

ebsite:  www.harvestfoundation.org. Sections:  Materials – LTDP II or LCMT Part 2

Disciple Nations Alliance online course:  www.disciplenations.org/resources/course.  Section:  Wholistic Ministry

*If Jesus Were Mayor*, Bob Moffitt and Karla Tesch.